# I - ផ្នែកកិច្ចការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

**អនុក្រឹត្យលេខ ២៩ អនក្រ**
**ស្តីពីការបង្កើតគណៈកម្មការទំនាក់ទំនង**
**ការងារជាមួយកងយោធពលភូមិន្ទ ថៃ**

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរាជក្រឹត្យចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

-ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខធានាសុវត្ថិភាព នៅតាមព្រំដែន កម្ពុជា-ថៃ

-តាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មការមួយ ដើម្បីទំនាក់ទំនងការងារជាមួយ កងយោធពលភូមិន្ទថៃ ចំណុះការដឹកនាំផ្ទាល់របស់ សម្តេចនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ និងជាសហអគ្គមេបញ្ជាការ នៃ កងយោធពលខេមរភូមិន្ទ ដែលរួមមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ទៀ បាញ់** រដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសហប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ធា ចំរាត់** រដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសហប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ប៉ុល សារឿន** នាយរងអគ្គសេនាធិការ ជាអនុប្រធាន

៤_ឯកឧត្តម អ៊ុង ស៊ាន អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៥_លោកឧត្តមសេនីយ៍ ចំរើន ជាតិ មេបញ្ជាការការពារព្រំដែន ជាសមាជិក

៦_លោកឧត្តមសេនីយ៍ ជា សុភ្ជា នាយកវិទ្យាល័យទី ២ អសធ ជាសមាជិក

៧_លោកឧត្តមសេនីយ៍ ឈុំ សុជាតិ នាយក្រុមស្រាវជ្រាវ អសធ ជាសមាជិក

៨_លោកឧត្តមសេនីយ៍ ឡាយ ម៉ិនសុខ នាយកនាយកដ្ឋានទាក់ទងអន្តរជាតិ ជាសមាជិក

៩_លោកឧត្តមសេនីយ៍ ស៊ឹក ឌី មេបញ្ជាការយោធភូមិភាគទី ៣ ជាសមាជិក

១០_លោកឧត្តមសេនីយ៍ ជួប សុខុន មេបញ្ជាការរងយោធភូមិភាគទី ៥ ជាសមាជិក

១១_លោកឧត្តមសេនីយ៍ ខាន់ សាវឿន មេបញ្ជាការយោធភូមិភាគទី ៤ ជាសមាជិក

១២_លោកឧត្តមសេនីយ៍ អ៊ុង សំខាន់ មេបញ្ជាការកងនាវាចរខេមរភូមិន្ទ ជាសមាជិក

១៣_អ្នកអង្គម្ចាស់ឧត្តមសេនីយ៍ នរោត្តម ម៉ាក់ ម៉ាន់នី មេបញ្ជាការកងអាកាសចរខេមរភូមិន្ទ ជាសមាជិក

**មាត្រា ២ :** ចាត់តាំងគណៈអចិន្ត្រៃយ៍សំរាប់ជំនួយដល់គណៈកម្មការសំរាប់ដោះស្រាយការងារប្រចាំថ្ងៃ ដែលរួមមានសមាសភាពដូចខាងក្រោម :

១_ឯកឧត្តម ឧត្តមសេនីយឯក ប៉ុល សារឿន ជាប្រធាន

២_លោក ឧត្តមសេនីយ៍ ចំរើន ជាតិ ជាសមាជិកអចិន្ត្រៃយ៍

៣_លោក ឧត្តមសេនីយ៍ ជា សុភ្ជា ជាសមាជិកអចិន្ត្រៃយ៍

៤_លោក ឧត្តមសេនីយ៍ ឈុំ សុជាតិ ជាសមាជិកអចិន្ត្រៃយ៍

៥_លោក ឧត្តមសេនីយ៍ ប្រាក់ ម៉ារឌី ជាសមាជិក

៦_លោក ឧត្តមសេនីយ៍ ឡាយ ម៉ិនសុខ ជាសមាជិក

៧_លោក ឧត្តមសេនីយ៍ កែវ ឈួន ជាសមាជិក

៨_លោក ឧត្តមសេនីយ៍ យឹម សាធី ជាសមាជិក

៩_លោក វរសេនីយ៍ ឈួន ចំនួនឆាយា ជាសមាជិក

**មាត្រា ៣ :** ដើម្បីជំនួយដល់គណៈកម្មការនេះក្នុងការសហការដោះស្រាយការងារបានល្អ នៅតាមភូមិសាស្ត្រនិមួយៗ ចាំបាច់ត្រូវរៀបចំអនុគណៈកម្មការនិងក្រុមការងារប្រមូលព័ត៌មានប្រចាំការតាមបណ្តាពិសេស

នៃយោធភូមិភាគនិមួយៗ ។ ចំពោះសមាសភាពនិងភារកិច្ចរបស់អនុគណៈកម្មការ និងក្រុមការងារនិមួយៗ អាស្រ័យដោយ គណៈកម្មការជាអ្នករៀបចំ និងកំណត់ជាក់ស្តែង ។

**មាត្រា ៤ :** គណៈកម្មការនេះមានភារកិច្ចសហការជាមួយកងយោធពលភូមិន្ទថៃ ដើម្បីពិគ្រោះគ្នាដោះស្រាយអោយបានល្អ នូវរាល់បាតុភាព ឧប្បត្តិហេតុផ្សេងៗដែលកើតឡើងនៅតាមព្រំដែន កម្ពុជា_ថៃ បង្កើតឡើងនូវបរិយាកាស សន្តិសុខ សុវត្ថិភាព នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ។

**មាត្រា ៥ :** ទីកន្លែងធ្វើការរបស់គណៈអចិន្ត្រៃយ៍ នៃ គណៈកម្មការកំណត់យកទីបញ្ជាការដ្ឋានការពារព្រំដែនអគ្គសេនាធិការ ។

**មាត្រា ៦ :** គណៈកម្មការមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។
គណៈអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

**មាត្រា ៧ :** ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ១៦ មករា ១៩៩៥ ។

**មាត្រា ៨ :** ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ និង សាមីជនដែលមានឈ្មោះក្នុងប្រការ ១និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ៣០ អនក្រ
## ស្តីពីការបង្កើតគណៈកម្មាធិការឥណទាន
## សំរាប់អភិវឌ្ឍន៍ជនបទ

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com